អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ទ្រព្យសកម្មរបស់វិស័យធនាគារ បានកើនឡើង១៨%(២២២ទ្រីលានរៀល) នាពាក់កណ្ដាលឆ្នាំ២០២១
- CDC បានអនុម័តគម្រោងវិនិយោគថ្មីចំនួន ៧១លានដុល្លារ ដែលអាចបង្កើតការងារ៩៥០០កន្លែង
- កម្ពុជាចាប់ផ្ដើមអនុវត្តច្បាប់ស្ដីពី «កិច្ចការពារអ្នកប្រើប្រាស់»
- ការនាំចេញអង្កររបស់កម្ពុជាធ្លាក់ចុះ២៧% ខណៈដែលតម្រូវការអង្ករពីចិន និងវៀតណាមកើនឡើង
- កសិករខ្មែរនៅតាមខេត្តជាប់ព្រំដែនវៀតណាម ត្អូញត្អែរពីការធ្លាក់ចុះតម្លៃស្រូវ
- ពាណិជ្ជកម្មរវាងកម្ពុជា និងថៃសម្រេចបានជិត ៤ពាន់លានដុល្លារ ធ្លាក់ចុះ១% នៅឆមាសទី១ ឆ្នាំ២០២១
- ទំហំពាណិជ្ជកម្មរបស់វៀតណាម ក្នុងរយៈពេល ០៥ ខែដំបូងនៃឆ្នាំ២០២១
- ពាណិជ្ជកម្មថៃ សម្រាប់រយៈពេល០៦ខែដំបូង នៃឆ្នាំ២០២១
- រោងចក្រនៅតំបន់អាស៊ី រងផលប៉ះពាល់ដោយសារការឡើងថ្លៃទំនិញ និងការផ្ទុះមេរោគបំប្លែងថ្មី "ដែលតា"
- ទំនុកចិត្តអ្នកប្រើប្រាស់របស់ជប៉ុន ហក់ឡើងខ្ពស់ក្នុងខែកក្កដា ២០២១ ក្នុងរយៈពេល ១៧ខែចុងក្រោយ
- កំណើនការផលិតរបស់ចិន ធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងខែកក្កដា ២០២១ ក្នុងរយៈពេល ១៥ខែចុងក្រោយ
- ប្រទេសចិន មើលឃើញពីកំណើនសេដ្ឋកិច្ចឌីជីថល លឿនបំផុត ក្នុងឆ្នាំ២០២០
- សូចនាករអតិផរណាសំខាន់ៗកើន៣,៥% ប្រចាំឆ្នាំនាខែមិថុនា កើនឡើងលឿនបំផុតចាប់តាំងពីឆ្នាំ ១៩៩១
- រតនាគារអាមេរិកព្យួរការទូទាត់ប្រាក់ចូលនិវត្តន៍បុគ្គលិករដ្ឋ និងមូលនិធិសុខភាព នាពេលកំណត់កម្រិតបំណុលឡើងវិញ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច
សប្តាហ៍ទី១ ខែសីហា ឆ្នាំ២០២១

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ទ្រព្យសកម្មរបស់វិស័យធនាគារ បានកើនឡើង១៨% (២២២ទ្រីលានរៀល) នាពាក់កណ្តាលឆ្នាំ២០២១



*ប្រភព៖ Cambodia Express News, 2021*

គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១នេះ ទ្រព្យសកម្មរបស់វិស័យធនាគារ បានកើនឡើង១៨% គឺកើនដល់ ២២២ ទ្រីលានរៀល(ស្មើនឹង៥៥,១ប៊ីលានដុល្លារអាមេរិក)។

ក្នុងឆមាសទី១ឆ្នាំ ២០២១នេះ ឥណទានអតិថិជនកើនឡើង ១៩,១% គឺមានចំនួន១៣៦,៦ទ្រីលានរៀល (ស្មើនឹង ៣៣,៩ប៊ីលានដុល្លារអាមេរិក) ទៅលើផ្នែកសំខាន់ៗ ដូចជាការជួញដូរដុំ និងរាយ ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធផ្ទាល់ខ្លួន និងសំណង់។ ទន្ទឹមនេះ ប្រាក់បញ្ញើបានកើនឡើង ២០,៨% គឺមានចំនួន១៣២,១ទ្រីលានរៀល(ស្មើនឹង ៣២,៧ប៊ីលានដុល្លារអាមេរិក)។

ដោយឡែក ទ្រព្យសកម្មនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានកើនឡើង ១៤,២% មានចំនួន ៣៦,២ ទ្រីលានរៀល(ស្មើនឹង ៨,៩ ប៊ីលានដុល្លារអាមេរិក)។ ឥណទានអតិថិជនបានកើនឡើង១៩,៣% មានចំនួន៣០,៧ទ្រីលានរៀល(ស្មើនឹង៧,៦ប៊ីលានដុល្លារអាមេរិក)ទៅលើផ្នែកសំខាន់ៗដូចជាឥណទានក្រុមគ្រួសារ កសិកម្ម ពាណិជ្ជកម្ម និងជំនួញ។ ទន្ទឹមនេះ ប្រាក់បញ្ញើវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើង ១៩,៣% ដល់១៥,៧ ទ្រីលានរៀល (ស្មើនឹង ៣,៩ប៊ីលានដុល្លារអាមេរិក)៕

*ដោយ មែន ខេមរៈ*

*ប្រភព ៖ CEN ចេញផ្សាយនាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១*

### ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគថ្មីចំនួន ៧១លានដុល្លារ ដែលអាចបង្កើតការងារចំនួន ៩៥០០កន្លែង



*ប្រភព៖ khmertimess, 2021 រូបភាព៖ KT/Chor Sokunthea and Khem Sovannara*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) បានអនុម័តគម្រោងថ្មីចំនួន០៨គម្រោងដែលមានទឹកប្រាក់ ៧១,៤លានដុល្លារ។ គម្រោងថ្មីទាំងនេះនឹងបង្កើតការងារជាង ៩ ៥០០កន្លែង ដែលជាចំណុចសំខាន់នៃការស្តារសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

គម្រោងថ្មីទាំងនេះបានចុះបញ្ជីរួចរាល់ហើយដល់ក្រុមហ៊ុនរួមមាន៖ Hong Cen Max Leather Products,

Remstex Fashion, Top Form (Cambodia) Manufacturing, New Wide Apparel, Cathaya (Cambodia), CK Sports, General Enterprises Garment (Cambodia) and Sortics Alliance ដែលមាទីតាំងនៅតាមបណ្តាខេត្តមួយចំនួនដូចជាៈ កណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង និងក្រុងព្រះសីហនុ។

សម្រាប់ខេត្តកណ្តាលមានគម្រោងចំនួនបី។ ក្រុមហ៊ុន Hong Cen Max មានគម្រោងសាងសង់រោងចក្រផលិតកាបូបនិងខ្សែក្រវ៉ាត់ ក្នុងទំហំទឹកប្រាក់វិនិយោគ ២,៦ លានដុល្លារ ដែលនឹងបង្កើតការងារចំនួន ៦៧៦កន្លែង។ ក្រុមហ៊ុនTop Form កំពុងសាងសង់រោងចក្រកាត់ដេរ ក្នុងទំហំទឹកប្រាក់វិនិយោគ ៩,៥ លានដុល្លារ ដែលនឹងផ្តល់ការងារដល់មនុស្ស ៨៥០ នាក់។ ក្រុមហ៊ុនមួយទៀតនោះគឺ ក្រុមហ៊ុន New Wide Apparel ដែលជាគម្រោងរោងចក្រកាត់ដេរដែលមានទឹកប្រាក់ ៣៣ លានដុល្លារ នឹងអាចបង្កើតការងារបានចំនួន ៣ ៧០០ កន្លែង។

សម្រាប់ខេត្តតាកែវមាន ក្រុមហ៊ុន Remstex Fashion ដែលបានវិនិយោគទឹកប្រាក់ចំនួន ៦លានដុល្លារក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលនឹងបង្កើតការងារបាន ១ ៩២៩ កន្លែងបន្ថែមទៀត។

ចំណែកឯខេត្តស្វាយរៀងមានក្រុមហ៊ុន CK Sports ផលិតស្បែកជើងនិងឧបករណ៍កីឡា ក្នុងរោងចក្រដែលមានទំហំវិនិយោគ ៥ លានដុល្លារក្នុងតំបន់សេដ្ឋកិច្ចពិសេសម៉ាន់ហាតាន់ ដែលនឹងផ្តល់ការងារដល់អ្នកនៅក្នុងតំបន់ប្រហែល ២១០ នាក់។ ដោយឡែក ខេត្តកំពង់ឆ្នាំង មានក្រុមហ៊ុន Sortics Alliance ដែលមានទំហំទឹកប្រាក់វិនិយោគ ៥,២ លានដុល្លារលើរោងចក្រកាត់ដេរសម្លៀកបំពាក់ ហើយគម្រោងនេះនឹងបង្កើតការងារចំនួន ១ ០៣៦ កន្លែង។

ទន្ទឹមនឹងនេះផងដែរ ក្រុងព្រះសីហនុនឹងទទួលបានរោងចក្រវាយនភ័ណ្ឌតម្លៃ ២,៨ លានដុល្លារដោយមានការអនុញ្ញាតពីក្រុមហ៊ុន Cathaya នឹងផ្តល់ការងារប្រហែល ១៧០ នាក់។

ជំងឺកូវីដ-១៩ បានប៉ះពាល់ដល់ការផលិតយ៉ាងធ្ងន់ធ្ងរបង្ខំឱ្យរោងចក្របិទទ្វារ និងក្រុមហ៊ុនជាច្រើនបានចាកចេញពីអាជីវកម្ម ដូច្នេះការវិនិយោគថ្មី នឹងក្លាយជាការស្វាគមន៍ សម្រាប់ការផលិតសម្លៀកបំពាក់ដែលជាការវិនិយោគធំបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា។

យោងតាមទិន្នន័យក្រសួងឧស្សាហកម្មបានបង្ហាញថា កាលពីឆ្នាំមុន រោងចក្រចំនួន ១០១ ត្រូវបានបិទទ្វារ ដែលភាគច្រើនជាផ្នែកកាត់ដេរ។ តួលេខនេះបានកើនឡើងនៅពាក់កណ្តាលខែឧសភាឆ្នាំនេះ ដោយមានរោងចក្រចំនួន ២៧ បានបិទទ្វារ ដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ-១៩ និង រោងចក្រចំនួន ៧៥ បានក្ស័យធន៕ *ដោយ សេន ចន្ធី*

*ប្រភព៖[khmertimes](khmertimes). ចេញផ្សាយថ្ងៃទី០២ខែសីហា ឆ្នាំ២០២១*

## កម្ពុជាចាប់ផ្តើមអនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដើម្បីជំរុញការប្រកួតប្រជែង ក្នុងវិស័យពាណិជ្ជកម្ម



*ប្រភព ៖ freshnewsasia, ២០២១*

ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១។ ច្បាប់នេះមានគោលដៅ បង្កើតបាននូវបរិយាកាសនៃការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្ម សេវាកម្ម ប្រកបដោយយុត្តិធម៌ សមធម៌ ផ្តល់នូវទំនុកចិត្តរវាងអ្នកប្រើប្រាស់ និងធុរជន ដែលជាកត្តាជំរុញឱ្យមានកំណើនអតិថិជនសម្រាប់ធុរជន ដែលប្រកបអាជីវកម្មដោយសុច្ចរិត។

ករណីមានបទល្មើស វិធានការមួយចំនួននឹងត្រូវអនុវត្តរួមមាន ៖ វិធានការពិន័យអន្តរការណ៍ ទណ្ឌកម្មផ្នែករដ្ឋបាល និងទណ្ឌកម្មដោយតុលាការមានសមត្ថកិច្ច។ រហូតមកដល់ពេលនេះ មន្ត្រីស៊ើបអង្កេតបានរកឃើញបទល្មើសមួយចំនួន នៅតាមទីតាំង អាជីវកម្មមួយចំនួន ហើយបានអនុវត្តវិធានការពិន័យអន្តរការណ៍ចំពោះម្ចាស់អាជីវកម្ម ដែលបានប្រព្រឹត្តបទល្មើសផងដែរ។

យោងតាមនីតិវិធីពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់នេះ មន្ត្រីស៊ើបអង្កេត មានភារកិច្ច ៖

*ចេញកំណត់ត្រាស្តីពីបណ្តឹពិន័យអន្តរការណ៍

*ចេញវិក្កយបត្របង់ប្រាក់ពិន័យអន្តរការណ៍ ទទួលប្រាក់ពិន័យអន្តរការណ៍ និងចេញបង្កាន់ដៃបង់ប្រាក់ដល់បុគ្គលល្មើស ក្នុងករណីទទួលប្រាក់ពិន័យអន្តរការណ៍ដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ

*គ្រប់គ្រងវិក្កយបត្រ បង្កាន់ដៃបង់ប្រាក់ និងប្រាក់ចំណូលពីការពិន័យអន្តរការណ៍

*ចេញលិខិតជូនដំណឹងក្រើនរំលឹកចំពោះបុគ្គលល្មើស ឱ្យមកបង់ប្រាក់ពិន័យអន្តរការណ៍ មិនឱ្យហួសកាលបរិច្ឆេទចុងក្រោយ ក្នុងករណីបុគ្គលនោះមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល១៥ថ្ងៃ

* កសាងសំណុំរឿងទៅតុលាការ ករណីជនល្មើស មិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមពេលកំណត់។

ការអនុវត្តវិធានការច្បាប់ចំពោះអំពើល្មើស គឺដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ទប់ស្កាត់អំពើមិនសុច្ចរិត ការពារផលប្រយោជន៍ពាណិជ្ជករ បង្កើនផលិតភាព និងជំរុញឱ្យការប្រកួតប្រជែង ក្នុងវិស័យពាណិជ្ជកម្មប្រព្រឹត្តទៅប្រកបដោយសមធម៌៕ *ដោយម៉ែន ខែមរៈ*

*ប្រភព ៖ FRESH NEWS ចេញផ្សាយថ្ងៃទី 2021-07-15 ១៥ ខែកក្កដា ឆ្នាំ២០២១*

## ការនាំចេញអង្ករបស់កម្ពុជា ធ្លាក់ចុះ២៧% ខណៈតម្រូវការអង្ករពីចិន និងវៀតណាមមានការកើនឡើង



*ប្រភព៖ khmertimes, 2021*

យោងតាមការលើកឡើងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថា ការនាំចេញអង្ករទៅក្រៅប្រទេសរបស់ប្រទេសកម្ពុជាគិតចាប់ពីខែមករា ដល់ខែកក្កដា បានធ្លាក់ចុះ ២៧,៣%ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។ ការធ្លាក់ចុះនេះបណ្តាលមកពី កង្វះធុងផ្ទុកទំនិញ និងការកើនឡើងនៃថ្លៃដើមដឹកជញ្ជូន។ ក្នុងអំឡុងពេលនេះប្រទេសកម្ពុជាបាននាំចេញអង្ករជិត ៣១ម៉ឺនតោន ដែលបានបង្កើតប្រាក់ចំណូលប្រមាណ ២៦២លានដុល្លារ សម្រាប់ក្រុមហ៊ុននាំចេញចំនួន ៥៨ ក្រុមហ៊ុន។

សូមបញ្ជាក់ផងដែរ ប្រទេសចិននៅតែជាទីផ្សារធំបំផុត ក្នុងចំណោមប្រទេស៤៩ ដែលធ្វើការនាំចូលអង្ករពី

ប្រទេសកម្ពុជា ដែលបច្ចុប្បន្នប្រទេសចិនបានទិញអង្ករជិត ១៥៤ពាន់តោន។ ចំណែកទីផ្សារផ្សេងទៀតរួមមានបណ្ដាប្រទេសនៃតំបន់អឺរ៉ុបចំនួន ២១ និងនៅអាស៊ីអាគ្នេយ៍ចំនួន៥ ក្នុងនោះប្រទេសវៀតណាមបានទិញអង្ករចំនួន ៨១%ច្រើនជាងឆ្នាំមុន ដែលផ្ដល់ប្រាក់ចំណូលបាន ៣៣០លានដុល្លារ។

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសកាត់បន្ថយការព្យាករ កំណើនសេដ្ឋកិច្ចរបស់ប្រទេសនៅឆ្នាំ ២០២១ មកត្រឹម ២,៥%បន្ទាប់ពីការព្យាករដំបូងមាន ៤% ដោយសារតែផលប៉ះពាល់សេដ្ឋកិច្ចនៃជំងឺរាតត្បាតរាតលើតម្រូវការផលិតផលកម្ពុជា។

ស្របពេលជាមួយគ្នានេះដែរ សហព័ន្ធស្រូវអង្ករកម្ពុជាបានបើកកិច្ចប្រជុំបន្ទាន់មួយដើម្បីពិភាក្សាពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើក្រុមហ៊ុននាំចេញនិងរោងម៉ាស៊ីនកិនស្រូវ ដែលការប្រជុំនេះផ្ដោតលើកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការស្វែងរកអ្នកទិញបន្ថែមនៅក្នុងប្រទេសចិន និងទីផ្សារអាស៊ីដទៃទៀត ដោយសារតែការដឹកជញ្ជូនអង្ករទៅកាន់អឺរ៉ុបកំពុងជួបប្រទះនូវបញ្ហា៕ *ដោយ សេន ចន្ទី*

*ប្រភព៖ khmertimes. ចេញផ្សាយថ្ងៃទី០៣ខែសីហាឆ្នាំ២០២១*

## កសិករខ្មែរ នៅតាមបណ្ដាខេត្តជាប់ព្រំដែនវៀតណាម ត្អូញត្អែពីធ្លាក់ចុះនៃតម្លៃស្រូវ



*ប្រភព៖ ភ្នំពេញ ប៉ុស្តិ៍ ២០២១ រូបភាព៖ ហ៊ាន រង្សី*

ប្រជាកសិករនៅតាមបណ្ដាខេត្តជាប់ព្រំដែនវៀតណាម បានត្អូញត្អែអំពីការធ្លាក់ចុះតម្លៃស្រូវ នៅក្នុងទីផ្សារក្នុងស្រុក ដោយសារការដឹកចេញទៅលក់នៅក្នុងប្រទេសវៀតណាមជួបការរាំងស្ទះ។ ការណ៍នេះ បណ្ដាលមកពីច្រកព្រំដែនរវាងប្រទេសទាំង២ ត្រូវបានបិទជាបណ្ដោះអាសន្ន ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ ហើយក្រុមឈ្មួញកណ្ដាលនៅក្នុងស្រុក បានទម្លាក់តម្លៃស្រូវពី ៩០០រៀលមកនៅត្រឹម ៦៥០ រៀលប៉ុណ្ណោះក្នុង១គីឡូក្រាម។ តម្លៃនេះបានធ្វើឱ្យកសិករខាតបង់ប្រាក់ចំណូលរាប់លានរៀល បើធៀបទៅនឹងតម្លៃទីផ្សារស្រូវនៅក្នុងប្រទេសវៀតណាម ដែលធ្លាប់បានដឹកទៅលក់នាពេលកន្លងមក។

ប្រជាកសិករ បានបង្ខំចិត្តលក់ស្រូវឱ្យឈ្មួញកណ្ដាល ព្រោះគ្មានជម្រើស ដោយត្រូវការលុយមកទូទាត់ថ្លៃដើមដែលបានខ្ចី យកមកធ្វើស្រូវ និងដោះស្រាយជីវភាពប្រចាំថ្ងៃ។

ប្រជាកសិករនៅក្នុងស្រុកកំពង់រោទិ៍ ភាគច្រើនធ្លាប់បាននាំគ្នាដឹកជញ្ជូនស្រូវដែលប្រមូលផលបាន ទៅលក់នៅ

ទីផ្សារវៀតណាម តាមច្រកអន្តរជាតិព្រៃវល្លិ៍ ក្នុងតម្លៃពី ៩០០រៀលទៅ ១ ០៥០ រៀលក្នុង១ គីឡូក្រាម។ ប៉ុន្តែដោយសារថ្មីៗនេះ នៅប្រទេសវៀតណាមមានបញ្ហាផ្ទុះឆ្លងជំងឺកូវីដ១៩ ច្រើនខ្លាំងពេក អាជ្ញាធរកម្ពុជា ក៏ដូចជាអាជ្ញាធរប្រទេសវៀតណាមបានឯកភាព បិទច្រកព្រំដែននៃប្រទេសទាំង ២ ជាបណ្តោះអាសន្ន។

បច្ចុប្បន្ន ក្រុមឈ្មួញកណ្តាលនៅក្នុងស្រុកហ៊ានឱ្យតម្លៃត្រឹមតែ៨០០រៀលប៉ុណ្ណោះសម្រាប់ប្រភេទស្រូវផ្ការំដួល ដែលកាលពីមុនពេលបិទច្រកព្រំដែន ឈ្មួញពីប្រទេសវៀតណាមចូលមកប្រមូលទិញដល់ក្នុងភូមិ ហ៊ានឱ្យថ្លៃដល់ ១ ១៥០រៀលក្នុង១គីឡូក្រាម។ ដូច្នេះ ការបាត់បង់ផលចំណេញមានរហូតដល់ ១,៤ លានរៀលក្នុង ១ ហិកតា។ មានការលើកឡើងថា ក្រុមឈ្មួញកណ្តាលបានឆក់យកឱកាសនេះ ទម្លាក់ថ្លៃស្រូវ ដោយលើកហេតុផលថា ពួកគេមានការចំណាយច្រើនទៅលើថ្លៃកម្មករ ថ្លៃសម្ងួតស្រូវ ថ្លៃដឹកជញ្ជូន និងថ្លៃចំណាយទៅលើសេវាផ្សេងៗទៀត។

លោកថន មឿន ដែលជាមន្ត្រីនគរបាលនៅឃុំជ្រៃ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានផ្ទៃដី៧ ហិកតាក៏បានលើកឡើងថា សម្រាប់ការធ្វើស្រូវផ្ការំដួល ចំណាយថ្លៃដើម ក្នុង១ហិកតា អស់ពីចន្លោះ ១,៥លាន ទៅ ២លានរៀល សម្រាប់តែទិញជី និងថ្នាំកសិកម្ម ថ្លៃភ្ជួររាស់ដីសាំងបូមទឹកបញ្ចូលស្រែ ច្រូតកាត់ និងថ្លៃដឹកជញ្ជូន។ រីឯផលស្រូវដែលប្រមូលបាន ពី ៤ ទៅ ៥ តោន ក្នុង ១ ហិកតា។

ជុំវិញករណីនេះ ប្រធានមន្ទីរកសិកម្មខេត្តព្រៃវែងបានលើកឡើងថា លោកគ្មានរំពឹងថាច្រកព្រំដែនរវាងកម្ពុជា និងវៀតណាមអាចនឹងចាប់ផ្តើមបើកឡើងវិញ តាមកាលកំណត់នាពេលឆាប់ៗនោះទេ ខណៈស្ថានភាពជំងឺកូវីដ ១៩ និង ជំងឺកូវីដបំប្លែងខ្លួនប្រភេទថ្មី Delta កំពុងបន្តការឆ្លងរាលដាលកាន់តែធ្ងន់ធ្ងរឡើង។ ពេលនេះ យើងកំពុងតាមដាននូវស្ថានភាពនៃជំងឺកូវីដ ១៩ បើខាងវៀតណាម មានការថយចុះនៃចំនួនអ្នកឆ្លងថ្មីនោះ ច្រកទ្វារព្រំដែនអាចនឹងបើកដំណើរការឡើងវិញ ប៉ុន្តែបើករណីឆ្លងនៅតែបន្តកើនឡើង ការបិទច្រកអាចនឹងពន្យារពេលយូរជាងនេះ។ ទោះយ៉ាងណា មន្ទីរកសិកម្ម កំពុងរិះរកមធ្យោបាយ ដើម្បីរក្សាតម្លៃស្រូវកុំឱ្យធ្លាក់ថ្លៃជាងនេះ។

តម្លៃស្រូវនាពេលបច្ចុប្បន្នសម្រាប់ខេត្តព្រៃវែង ជាមធ្យមបានធ្លាក់មកនៅក្នុងតម្លៃពី ៦៥០រៀល ទៅ ៧៥០ រៀលក្នុង ១ គីឡូក្រាម ដែលជាតម្លៃនៃការប្រមូលទិញរបស់ឈ្មួញកណ្តាល។ ប៉ុន្តែនៅតំបន់ខ្លះ មានការប្រមូលទិញក្នុងតម្លៃខ្ពស់ជាងនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២១*

## ពាណិជ្ជកម្មទំនិញរវាងកម្ពុជា និងថៃ សម្រេចបានជិត ៤ ពាន់លានដុល្លារ ធ្លាក់ចុះ១%នៅឆមាសទី១ ឆ្នាំ២០២១



*ដោយ ខេមបូណូមីស*

ស្ថានភាពដោះដូរទំនិញរវាងប្រទេសកម្ពុជា និងថៃ ហាក់មានសភាពល្អប្រសើរឡើងវិញគួរឱ្យកត់សម្គាល់ នៅប៉ុន្មានខែចុងក្រោយនេះ។ ជាក់ស្តែងនៅខែមិថុនា

កន្លងទៅ ការនាំចេញពីកម្ពុជា ទៅថៃ បានកើនដល់ ៤២% និងការនាំចូលពីថៃមកវិញ កើនដល់២៩%។ ក្នុងនោះ ចំនួនទឹកប្រាក់នៃការនាំចេញរបស់កម្ពុជាក្នុងខែមិថុនាកន្លង មាន ៥៦លានដុល្លារអាមេរិក កើនឡើង៤២%ធៀបនឹងខែមិថុនា ឆ្នាំ២០២០ ដែលមានត្រឹមជាង ៣៩លានដុល្លារ។ ចំណែកឯការនាំចូលពីថៃក្នុងខែមិថុនានៃឆ្នាំ២០២១វិញ មានទំហំ ៥៦០លានដុល្លា កើនឡើង២៩% ធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ទឹកប្រាក់សរុប នៃការដោះដូរពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងថៃ នៅរយៈពេល៦ខែ ដើមឆ្នាំនេះមានតម្លៃ ៣ ៩៨២លានដុល្លារ ធ្លាក់ចុះ១% បើធៀបទៅរយៈពេលដូចគ្នានៃ២០២០ ដែលមានទឹកប្រាក់ ៤,០២៥ លានដុល្លា។ ក្នុងនោះ ការនាំចេញសរុបរបស់កម្ពុជាទៅថៃ មានតម្លៃ ៥១២លានដុល្លា ធ្លាក់ចុះ៣៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ ដែលមានទឹកប្រាក់ ៧៦៥លានដុល្លារ។ រីឯ ការនាំចូលពីប្រទេសថៃមកវិញ មានតម្លៃ ៣ ៤៦៦លានដុល្លា ដែលបានកើនឡើង ៣%។ ប្រការនេះ បង្កើតឱ្យកម្ពុជាមានឱនភាពពាណិជ្ជកម្មនៃប្រទេសទាំងពីរ ចំនួន ជិត៣ពាន់លានដុល្លារអាមេរិក។

សូមបញ្ជាក់ថា ប្រទេសថៃ និងកម្ពុជា កំពុងទទួលរងនូវរលកឆ្លងកូវីដ-១៩កាន់តែខ្លាំងក្លា ដោយក្នុងនោះ ប្រទេសថៃ ហាក់កំពុងផុងខ្លួនកាន់តែជ្រៅជាងគេ បើធៀបនឹងប្រទេសផ្សេងៗទៀតក្នុងតំបន់។ នៅខែកក្កដា ឆ្នាំ២០២១ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសថៃ កាន់តែជួបបញ្ហា បើទោះបីជា រាជរដ្ឋាភិបាលថៃ ប្រឹងប្រែងដាក់ចេញយុទ្ធសាស្ត្រថ្មីៗដូចជា គម្រោងបើកកោះភូកេតទទួលភ្ញៀវទេសចរអន្តរជាតិដែលបានចាក់វ៉ាក់សាំង និងយុទ្ធនាការចាក់វ៉ាក់សាំងបង្ការកូវីដ-១៩ ដល់ពលរដ្ឋរបស់ខ្លួនយ៉ាងណាក្តី។

ធនាគារកណ្តាលថៃ បានព្យាករណ៍ថា ការបន្តការបិទខ្ទប់ប្រទេស ទប់ទល់នឹងរលកឆ្លងកូវីដ-១៩ នាពេលថ្មីៗនេះ នឹងធ្វើឱ្យសេដ្ឋកិច្ចថៃធ្លាក់ចុះ០,៨% សម្រាប់សេណារីយ៉ូល្អបំផុត នៅពេលអត្រាឆ្លងថ្មីធ្លាក់ចុះក្រោម ៤០% ក្នុងខែសីហា។ ប៉ុន្តែ សម្រាប់សេណារីយ៉ូអាក្រក់បំផុតវិញ សេដ្ឋកិច្ចថៃអាចនឹងត្រូវធ្លាក់ចុះប្រមាណ ២%ទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ការប្រៀបធៀបការអនុវត្តចំណូលថវិការដ្ឋ ខែឧសភា ឆ្នាំ២០២១




តារាងទី១៖ខាងលើនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូល ក្នុងខែឧសភា ឆ្នាំ២០២១ ដែលរាជរដ្ឋាភិបាលអនុវត្តបាន។ ចំណូលក្នុងស្រុកសរុបមានចំនួនប្រហែល ១ ៦៦៧ ប៊ីលានរៀល ឬ កើនជិត ១៣% បើធៀបនឹងខែឧសភា ឆ្នាំ២០២០ ដែលមានចំនួនជិត ១ ៤៨២ ប៊ីលានរៀល។ ក្នុងនោះ ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធអនុវត្តបាន ៨% និង ៥%

នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬ កើន ១៣,៣៩% និង ៣,៤០%រៀងគ្នា បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។

គិតត្រឹមរយៈពេល ០៥ខែ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលសរុប បានប្រមាណ ៩ ១៥១ប៊ីលានរៀល ឬស្មើនឹង ៤៦% នៃច្បាប់ឆ្នាំ២០២១ ខណៈដែលការអនុវត្តក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២០ សម្រេចបានត្រឹមតែ៤០%នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០។ បើទោះបីជាព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ បាននឹងកំពុងបន្តដាក់សម្ពាធដល់ការប្រមូលចំណូលថវិកាជាតិ ក្នុងឆ្នាំ ២០២១ ក៏ដោយ ក៏ការប្រមូលចំណូលក្នុងខែឧសភា ឆ្នាំ២០២១ ចាប់ផ្តើមមានសញ្ញាល្អប្រសើរឡើងវិញ៕

*ដោយ ឈន ហាំ*

*ប្រភព៖ ការអនុវត្តថវិកាជ្រ ខែធ្នូ ឆ្នាំ២០២០ និងខែឧសភា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១*

## តារាងទី២៖ ការប្រៀបធៀបការអនុវត្តចំណាយថ្នាក់ជាតិ ខែឧសភា ឆ្នាំ២០២១




តារាងទី២៖ខាងលើនេះ បង្ហាញពីការប្រៀបធៀបការអនុវត្តចំណាយ ក្នុងខែឧសភា ឆ្នាំ២០២១ ដែលរាជរដ្ឋាភិបាលអនុវត្តបាន។ ការចំណាយសរុបថ្នាក់ជាតិសម្រេចបានចំនួនប្រមាណ ១ ៨៤៨ ប៊ីលានរៀល ឬ កើន ២១% បើធៀបនឹងខែឧសភានាឆ្នាំ២០២០ ដែលមានចំនួនប្រហែល ១ ៥៣១ ប៊ីលានរៀល។

ក្នុងខែឧសភា ឆ្នាំ២០២១ ការចំណាយសរុបថ្នាក់ជាតិសម្រេចបាន ១ ៨៤៩ ប៊ីលានរៀល ឬ ស្មើនឹង ៦,៣១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលកើនឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។ កំណើននៃការអនុវត្តចំណាយក្នុងខែឧសភានេះ គឺដោយសារការចំណាយចរន្តលើរដ្ឋបាលស៊ីវិល ដែលសម្រេច បានប្រហែលចំនួន ៩៤៥ ប៊ីលានរៀល។

គិតត្រឹមរយៈពេល ០៥ខែ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិបានអនុវត្តការចំណាយសរុបថ្នាក់ជាតិ សម្រេចបានប្រហែលចំនួន ៨ ៩៨០ ប៊ីលានរៀល ឬស្មើនឹង ៣១% ដែលសម្រេចបានទាបជាងផែនការគ្រោងបន្តិច។

ជារួម បើទោះបីជា ការអនុវត្តចំណាយក្នុងឆ្នាំ២០២១ បានជួបឧបសគ្គនៃព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ ក៏ដោយ ក៏ការអនុវត្តចំណាយនេះ នូវតែប្រហាក់ប្រហែលនឹងការអនុវត្តចំណាយនាឆ្នាំកន្លងមកផងដែរ៕

*ដោយ ឈន ហាំ*

*ប្រភព៖ ការអនុវត្តថវិកាជ្រ ខែធ្នូ ឆ្នាំ២០២០ និងខែឧសភា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ទំហំពាណិជ្ជកម្មរបស់វៀតណាម ក្នុងរយៈពេល ០៥ ខែដំបូងនៃឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

តារាងខាងក្រោមបង្ហាញពីកំណើនពាណិជ្ជកម្មរបស់ប្រទេសវៀតណាម ជាមួយចិន ប្រទេសក្នុងសហគមន៍អឺរ៉ុប និងអាមេរិក ក្នុងរយៈពេល០៥ខែដំបូង នៃឆ្នាំ ២០២១។

ការនាំចេញរបស់វៀតណាមទៅកាន់ទីផ្សារអាមេរិកមានទំហំ ៣៧,៤៤ ពាន់លានដុល្លារ សម្រាប់រយៈពេល ០៥ខែដើមឆ្នាំនេះ ពោលគឺ កើនឡើង៤៩,៣% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការនាំចូលពីសហរដ្ឋអាមេរិកវិញ មានទំហំតែ ៦,៤៤ពាន់លានដុល្លារ សម្រាប់រយៈពេល០៥ខែដំបូងនៃឆ្នាំ២០២១ ដែលកើនឡើង ៨,២%។

ចំណែកឯ ការនាំចេញរបស់វៀតណាមទៅចិនមានទំហំ ២០,២៤ ពាន់លានដុល្លារ ខណៈការនាំចូលពីចិន មកវៀតណាមវិញ មានទំហំ ៤៣,៧៧ ពាន់លានដុល្លារ ក្នុងរយៈពេល០៥ខែដំបូងនៃឆ្នាំ២០២១។ ជារួម វៀតណាមមានឱនភាពពាណិជ្ជកម្មជាមួយចិនចំនួន ២៣,៥២ ពាន់លានដុល្លារ។

ដោយឡែក ការនាំចេញរបស់វៀតណាមទៅទីផ្សារសហគមន៍អឺរ៉ុបវិញ មានទំហំ១៦,១២ ពាន់លានដុល្លារ កើនឡើង ២១,៥% ក្នុងរយៈពេល០៥ខែដំបូងនៃឆ្នាំ ២០២១ ខណៈការនាំចូលមានតែ ៦,៧៩ ពាន់លានដុល្លារ ប៉ុន្តែមានកំណើន ១៨,៥%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន៕ *ដោយ ជីម ប៊ុនធឿន*

| | ទំហំពាណិជ្ជកម្ម | កំណើនប្រចាំឆ្នាំ (%) |
|---|---|---|
| **ការនាំចេញ** | | |
| ចិន | 20.24 | 27 |
| សហគមន៍អឺរ៉ុប | 16.12 | 21.5 |
| អាមេរិក | 37.44 | 49.3 |
| **ការនាំចូល** | | |
| ចិន | 43.76 | 55.2 |
| សហគមន៍អឺរ៉ុប | 6.79 | 18.5 |
| អាមេរិក | 6.44 | 8.2 |

*ប្រភព៖ Vietnam Customs*

### ពាណិជ្ជកម្មថៃ សម្រាប់រយៈពេល០៦ខែដំបូង នៃឆ្នាំ ២០២១ (គិតជាលានបាត)

រូបភាពខាងក្រោមបង្ហាញពីពាណិជ្ជកម្មរបស់ប្រទេសថៃ សម្រាប់រយៈពេល០៦ខែដំបូង នៃឆ្នាំ២០២១។

ការនាំចេញរបស់ថៃមានចំនួន ៧៣៨ ១៣៥លានបាត នៅក្នុងខែមិថុនា ឆ្នាំ២០២១ កើនឡើង ៣% បើធៀបនឹងការនាំចេញនៅក្នុងខែឧសភា ឆ្នាំ២០២១។ ជារួម ការនាំចេញរបស់ថៃ មានការកើនឡើងស្ទើរពល់ខែ សម្រាប់រយៈពេល០៦ខែ ដំបូងនៃដើមឆ្នាំនេះ ជាពិសេសនៅក្នុងខែមីនា ឆ្នាំ២០២១ មានកំណើននៃការនាំចេញដល់ ១៩,៥%ធៀបនឹងខែកុម្ភៈ ដែលជាកំណើនខ្ពស់បំផុតប្រចាំខែនៅដើមឆ្នាំនេះ។

ស្រដៀងគ្នានឹងការនាំចេញដែរ ការនាំចូលរបស់ថៃក៏មានកំណើនស្ទើរតែរាល់ខែ លើកលែងតែខែមេសា សម្រាប់រយៈពេល ០៦ខែ នៃឆ្នាំ២០២១។ ជាពិសេស

នៅក្នុងខែមីនា ឆ្នាំនេះ ការនាំចូលមានកំណើន ១៦,១% ធៀបនឹងការនាំចូលក្នុងខែកុម្ភៈ ដែលជាកំណើនខ្ពស់បំផុតសម្រាប់រយៈពេល០៦ នៃដើមឆ្នាំនេះ។

ដោយឡែក តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសថៃមានឱនភាពពីរខែដំបូងជាប់គ្នា (ខែមករា និងខែកុម្ភៈ) និងខែមេសា ឆ្នាំ២០២១។ ប៉ុន្តែ សម្រាប់ខែមិថុនា និងខែឧសភា ឆ្នាំ២០២១ ប្រទេសថៃមានអតិរេកពាណិជ្ជកម្ម ១៩ ៤៨៤លានបាត និង ១៤ ៩៦៧លានបាត រៀងគ្នា៕

*ដោយ ធីម ប៊ុនធឿន*




*ប្រភព៖ www.bot.or.th*

## សកម្មភាពរោងចក្រនៅតំបន់អាស៊ី រងផលប៉ះពាល់ដោយការកើនឡើងថ្លៃទំនិញ និងការផ្ទុះមេរោគបំប្លែងថ្មី "ដែលតា"



*ប្រភព ៖ SWIFT NEWS*

កាលពីខែកក្កដារោងចក្រនៅតំបន់អាស៊ី បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការកើនឡើងថ្លៃទំនិញ និងរលកថ្មីនៃការឆ្លងកូវីដ-១៩ ហើយបានគ្របដណ្ដប់លើតម្រូវការសកល ប៉ះពាល់កំណើនសេដ្ឋកិច្ច។ ទោះជាយ៉ាងណា សកម្មភាពផលិតបានកើនឡើងនៅក្នុងរោងចក្រថាមពលនាំចេញក្នុងប្រទេសជប៉ុន និងកូរ៉េខាងត្បូង ទោះបីជាក្រុមហ៊ុនបានទទួលរងពីការរំខានដល់សង្វាក់ផ្គត់ផ្គង់ និងកង្វះវត្ថុធាតុដើម ដែលនាំឱ្យថ្លៃកើនឡើងក៏ដោយ។

ការស្ទង់មតិឯកជនមួយបានបង្ហាញថា កំណើនសកម្មភាពរោងចក្ររបស់ចិន បានធ្លាក់ចុះយ៉ាងគំហុកនៅក្នុងខែកក្កដា ដោយសារតម្រូវការបានធ្លាក់ចុះជាលើកដំបូង ក្នុងរយៈពេលជាងមួយឆ្នាំចុងក្រោយនេះ។ ប្រទេសឥណ្ឌូនេស៊ី វៀតណាម និងម៉ាឡេស៊ី បានមើលឃើញពីសកម្មភាពផលិតកម្មធ្លាក់ចុះក្នុងខែកក្កដាផងដែរ ដោយសារការឆ្លងកូវីដ-១៩ផ្ទុះឡើង និងការរឹតត្បិតទប់ស្កាត់ការឆ្លងរាលដាល កាន់តែតឹងរ៉ឹងជាងមុន។

ការស្ទង់មតិនេះ បានបង្ហាញពីភាពខុសគ្នាដែលកើតឡើងនៅទូទាំងសេដ្ឋកិច្ចពិភពលោក ក្នុងល្បឿននៃការងើបឡើងវិញពីជំងឺរាតត្បាត ដែលនាំឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិ ទម្លាក់ចំណាត់ថ្នាក់ការព្យាករណ៍កំណើនសេដ្ឋកិច្ចនៅឆ្នាំនេះ សម្រាប់ប្រទេសកំពុងរីកចម្រើននៅក្នុងតំបន់អាស៊ី៕ *ដោយ ម៉ែនខែមរៈ*

*ប្រភព ៖ swiftnews ចេញផ្សាយថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១*

## ទំនុកចិត្តអ្នកប្រើប្រាស់របស់ជប៉ុន ក្នុងខែកក្កដា ២០២១ ហក់ឡើងខ្ពស់ក្នុងរយៈពេល ១៧ខែចុងក្រោយ




*ប្រភព៖ CNA ២០២១, រូបភាព៖REUTERS/Yuya Shino/File Photo*

យោងតាមការស្ទង់មតិរបស់រដ្ឋាភិបាលជប៉ុន ដែលទើបចេញផ្សាយនៅថ្ងៃចន្ទ សប្តាហ៍នេះ បានបង្ហាញថា ទំនុកចិត្តអ្នកប្រើប្រាស់របស់ជប៉ុនបានហក់ឡើងខ្ពស់ជាលើកដំបូងក្នុងរយៈពេល ១៧ខែ ក្នុងខែកក្កដា ឆ្នាំ២០២១ គិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២០ ដោយបានត្រឡប់មករកកម្រិតមុនការរាតត្បាតនៃជំងឺកូវីដ-១៩ វិញ បើទោះបីមានការផ្ទុះឡើងជាថ្មីនៃករណីឆ្លងជំងឺកូវីដ-១៩ ដែលបានបង្ខំឱ្យអាជ្ញាធរដាក់ចេញនូវវិធានការទប់ស្កាត់ថ្មីដោយដាក់ខេត្តមួយចំនួនដែលនីជិតទីក្រុងតូក្យូក្នុងស្ថានភាពអាសន្នក៏ដោយ។

ការស្ទង់មតិបានបង្ហាញថា សន្ទស្សន៍ទំនុកចិត្តអ្នកប្រើប្រាស់ដែលត្រូវបានកែសម្រួលតាមរដូវកាលរបស់ជប៉ុនមានចំនួន ៣៧,៥ នៅក្នុងខែកក្កដា ដែលកើនឡើងពី ៣៧,៤ ក្នុងខែមិថុនា ឆ្នាំ២០២១ ដែលជាកំណត់ត្រានៃការកើនឡើងជាប់គ្នាពីរខែ។
អ្នកប្រើប្រាស់មានសុទិដ្ឋិនិយមច្រើន នៅក្នុងខែកក្កដា អំពីជីវភាពរស់នៅ ការងារ និងប្រាក់ចំណូលរបស់ពួកគេជាងនៅក្នុងខែមិថុនា ឆ្នាំ២០២១ ដែលនេះ បង្ហាញថាការចំណាយរបស់រាជរដ្ឋាភិបាលដ៏ច្រើនសន្ធឹកសន្ធាប់ និងការនាំចេញដ៏រឹងមាំ បានជួយប៉ះប៉ូវពីផលប៉ះពាល់ដោយសារការធ្លាក់ចុះនៃតម្រូវការក្នុងស្រុក ។

រដ្ឋាភិបាលជប៉ុន ក៏បានបញ្ជាក់នៅក្នុងការស្ទង់មតិនេះផងដែរថា ទំនុកចិត្តអ្នកប្រើប្រាស់នៅតែបន្តងើបឡើងវិញ បើទោះបីជាប្រទេសកំពុងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។
យោងតាមអ្នកវិភាគមកពីវិទ្យាស្ថានស្រាវជ្រាវ Daiwa បានឱ្យដឹងថា ការខាតបង់នៃសេដ្ឋកិច្ចពីវិធានការទប់ស្កាត់ដោយដាក់ខេត្ត/ក្រុងស្ថិតក្នុងស្ថានភាពអាសន្នអាចនឹងមានកម្រិតទាបនៅក្នុងខែកក្កដា ហើយការខាតបង់នៃសេដ្ឋកិច្ចពីវិធានការថ្មី ដែលនឹងបន្តរហូតដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១ ខាងមុខ ត្រូវបានប៉ាន់ប្រមាណមានចំនួនប្រហែល ៣៥០ប៊ីលានយ៉េន (ឬស្មើនឹង ៣,១៩ប៊ីលានដុល្លារអាមេរិក)៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Channel News Asia ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១*

## កំណើនសកម្មភាពផលិតរបស់ចិន ក្នុងខែកក្កដា ឆ្នាំ២០២១ ធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេល ១៥ខែ

*ប្រភព៖ CNBC ២០២១, រូបភាព៖ Costfoto/Barcroft Media/Getty*

កំណើនសកម្មភាពផលិតរបស់ចិន បានធ្លាក់ចុះយ៉ាងគំហុកនៅក្នុងខែកក្កដា ឆ្នាំ២០២១ ដោយសារតម្រូវការធ្លាក់ចុះយ៉ាងខ្លាំងជាលើកដំបូងក្នុងរយៈពេលជាងមួយឆ្នាំនេះ ដែលបណ្តាលមកពីតម្លៃផលិតផលខ្ពស់ ដែលកំពុងបង្កបញ្ហាប្រឈមដល់មជ្ឈមណ្ឌលផលិតកម្មរបស់ពិភពលោក នេះបើយោងតាមរបាយការណ៍ស្ទង់មតិអាជីវកម្មដែលទើបចេញផ្សាយនៅថ្ងៃចន្ទ សប្តាហ៍នេះ។ សន្ទស្សន៍អ្នកគ្រប់គ្រងការបញ្ជាទិញផ្នែកផលិតកម្មរបស់ចិន Caixin/Markit Manufacturing Purchasing Managers' Index (PMI) បានធ្លាក់ចុះដល់ ៥០,៣ ក្នុងខែកក្កដា ពី ៥១,៣ ក្នុងខែមិថុនា ឆ្នាំ២០២១ ដែលជាកម្រិតទាបបំផុតចាប់ពីខែមេសា ឆ្នាំ២០២០។ ដោយឡែក ក្រុមអ្នកវិភាគដែលស្ទង់មតិដោយ Reuters បានរំពឹងថាសន្ទស្សន៍PMIនឹងធ្លាក់ចុះដល់ត្រឹម៥១,១។ ពិន្ទុ ៥០ គឺជាកម្រិតប្រៀបធៀបរវាងការកើនឡើង និងការធ្លាក់ចុះនៃមូលដ្ឋានប្រចាំខែ។

សេដ្ឋកិច្ចចិន បានងើបឡើងវិញយ៉ាងខ្លាំងពីការរំខានដោយជំងឺរាតត្បាតកូវីដ-១៩ ប៉ុន្តែ សេដ្ឋកិច្ចចិនបានប្រឈមនឹងបញ្ហាថ្មីៗក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ដែលមានដូចជាថ្លៃដើមវត្ថុធាតុដើមខ្ពស់ ដែលបានទាញចុះនូវកំណើនប្រាក់ចំណេញរបស់ក្រុមហ៊ុនឧស្សាហកម្មផលិត ក្នុងខែមិថុនា ឆ្នាំ២០២១។ ទោះជាយ៉ាងណា អ្នកតាក់តែងគោលនយោបាយរបស់ចិន បានបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការឡើងថ្លៃទំនិញ ដែលបានធ្វើឱ្យប៉ះពាល់ដល់កម្រិតប្រាក់ចំណេញរបស់ក្រុមហ៊ុនផលិត។

យោងតាមសម្តីរបស់លោក Wang Zhe សេដ្ឋវិទូជាន់ខ្ពស់ប្រចាំក្រុមហ៊ុន Caixin Insight Group ដែលមាននៅ



ក្នុងរបាយការណ៍ស្ទង់មតិបានបញ្ជាក់ថា «សេដ្ឋកិច្ចរបស់ចិន នៅតែប្រឈមនឹងសម្ពាធធ្លាក់ចុះខ្លាំង»។ តម្លៃផលិតផលខ្ពស់ បានធ្វើឱ្យតម្រូវការធ្លាក់ចុះ ជាពិសេសទំនិញប្រើប្រាស់ និងទំនិញពាក់កណ្តាលសម្រេច។ លោក បន្ថែមថា «តម្រូវការទីផ្សារងាយរងប៉ះទង្គិចទៅនឹងតម្លៃផលិតផល ដែលជាកត្តាកំណត់នូវអំណាចថ្លៃរបស់ក្រុមហ៊ុនផលិត»៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១*

## ប្រទេសចិន មើលឃើញពីកំណើនសេដ្ឋកិច្ចឌីជីថលលឿនបំផុត ក្នុងឆ្នាំ២០២០




*ប្រភព ៖ SWIFT NEWS ២០២១*

យោងតាមរបាយការណ៍មួយបានបង្ហាញថា សេដ្ឋកិច្ចឌីជីថលរបស់ចិន បានកើនឡើង៩,៦ % ក្នុងឆ្នាំ២០២០ ដែលជាអត្រាកំណើនលឿនបំផុតនៅទូទាំងពិភពលោក។

ដោយប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រទេសសេដ្ឋកិច្ចធំៗ បានខិតខំប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ដែលត្រូវបានគេមើលឃើញថា ជាសន្ទុះដ៏សំខាន់មួយ ក្នុងការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ ផ្លាស់ប្តូរលក្ខណៈប្រកួតប្រជែង និងកែលម្អអភិបាលកិច្ច។

នៅឆ្នាំ ២០២០ ទំហំសេដ្ឋកិច្ចឌីជីថលរបស់ប្រទេសចំនួន៤៧ ឈានដល់ ៣២,៦ ទ្រីលានដុល្លារ ដែលកើនឡើង ៣% ស្មើនឹង ៤៣,៧%នៃផលិតផលក្នុងស្រុកសរុប(GDP)។ ការធ្វើឌីជីថលឧស្សាហកម្ម ជាក្បាលម៉ាស៊ីនសំខាន់នៃកំណើនសេដ្ឋកិច្ចឌីជីថល។

សហរដ្ឋអាមេរិក បានបន្តនាំមុខគេលើពិភពលោក ទាក់ទងនឹងទំហំនៃសេដ្ឋកិច្ចឌីជីថល ដែលបានកើនដល់ ១៣,៦ ទ្រីលានដុល្លារនៅឆ្នាំ ២០២០ បន្ទាប់មកចិនចំនួន៥,៤ ទ្រីលានដុល្លារ អាល្លឺម៉ង់២,៥៤ ទ្រីលានដុល្លារ ជប៉ុន ២,៤៨ ទ្រីលានដុល្លារ និងចក្រភពអង់គ្លេស ១,៧៩ ទ្រីលានដុល្លារ។

*ដោយម៉ែន ខែមរៈ*

*ប្រភព ៖ SWIFT NEWS ចេញផ្សាយថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០២១*

## សេដ្ឋកិច្ចសកល

### សូចនាករអតិផរណាសំខាន់ៗកើនឡើង ៣,៥% ប្រចាំឆ្នាំគិតក្នុងខែមិថុនា ដែលកើនឡើងលឿនបំផុតចាប់តាំងពីឆ្នាំ ១៩៩១

ក្រសួងពាណិជ្ជកម្មអាមេរិក បានលើកឡើងពីសូចនាករអតិផរណាមួយដែលធនាគារកណ្តាលអាមេរិកប្រើជាមគ្គុទ្ទេសក៍គន្លឹះរបស់ខ្លួន បានកើនឡើង ៣,៥% នៅក្នុងខែមិថុនា ដែលជាការកើនឡើងយ៉ាងខ្លាំង ដូចទៅនឹងការរំពឹងទុករបស់ Wall Street ។ ជាមួយគ្នានេះ សន្ទស្សន៍ថ្លៃចំណាយលើការប្រើប្រាស់ដែលមិនរាប់បញ្ចូលអាហារ និងថាមពល ត្រូវបានគេរំពឹងថានឹងកើនឡើង ៣,៦% នៅពេលដែលសេដ្ឋកិច្ចអាមេរិក មានអត្រាអតិផរណាខ្ពស់បំផុតក្នុងរយៈពេលជាងមួយទសវត្សរ៍។ អត្រានេះ គឺខ្ពស់ជាងអត្រា ៣,៤% ក្នុងខែឧសភា ហើយជាការកើនឡើងធំបំផុតគិតចាប់តាំងពីខែកក្កដា ឆ្នាំ ១៩៩១។

តាមរយៈមន្ត្រីធនាគារកណ្តាល អតិផរណានឹងកើនឡើងជាបណ្តោះអាសន្ន ដោយសារភាគច្រើនបណ្តាលមកពីឧស្សាហកម្មដែលផ្សារភ្ជាប់នឹងការបើកដំណើរការសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាការជាប់គាំងខ្សែសង្វាក់ផ្គត់ផ្គង់ និងបញ្ហាផ្សេងទៀតដែលអាចនឹងធូរស្រាលវិញ ខណៈដែល ធនាគារកណ្តាល កំណត់គោលដៅ ២% ជាគោលដៅអតិផរណាដែលខ្លួនចង់បាន ។

ជាមួយគ្នានេះ ចំនួនចំណូល និងចំណាយបុគ្គល មានភាពល្អប្រសើរជាងការរំពឹងទុក ខណៈអតិថិជនបានប្រើប្រាស់កញ្ចប់សាច់ប្រាក់ជំរុញសេដ្ឋកិច្ច ដែលធ្វើឲ្យសេដ្ឋកិច្ចបន្តងើបឡើងវិញ។ ប្រាក់ចំណូល បានកើនឡើង ០,១% ប្រសើរជាងការប៉ាន់ស្មានថាអាចធ្លាក់ចុះ ០,២% ខណៈពេលដែលការចំណាយកើនឡើង ១%

ទល់នឹងការព្យាករណ៍ ០,៧%។ ទន្ទឹមនឹងនេះ អតិផរណាការងារ ក៏បន្តកើនឡើងដែរ។ *ដោយ វត្ថា វង្សវឌ្ឍនៈ ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០២១*

## រតនាគារអាមេរិកពន្យាការទូទាត់ប្រាក់ចូលនិវត្តន៍បុគ្គលិករដ្ឋាភិបាល និងមូលនិធិសុខភាព ខណៈកំណត់កម្រិតបំណុលរដ្ឋាភិបាលឡើងវិញ



*ប្រភព៖ Greg Nash/Pool via REUTERS/Files*

រដ្ឋមន្ត្រីក្រសួងរតនាគារអាមេរិក លោកស្រី Janet Yellen បានចាត់វិធានការបន្ថែមដើម្បីការពារសមត្ថភាពខ្ចីប្រាក់របស់រដ្ឋាភិបាលសហព័ន្ធនៅក្រោមដែនកំណត់បំណុលថ្មីឡើងវិញ ដោយព្យួរការវិនិយោគមួយចំនួន ចំពោះប្រាក់ចូលនិវត្តន៍របស់បុគ្គលិករដ្ឋាភិបាល និងមូលនិធិសុខភាព។

នៅក្នុងលិខិតមួយទៅកាន់ប្រធានសភាតំណាងរាស្ត្រ លោកស្រី Nancy Pelosi និងថ្នាក់ដឹកនាំសភាដទៃទៀត លោកស្រី Yellen បាននិយាយថាលោកស្រីកំពុងព្យួរការវិនិយោគនៅក្នុងមូលនិធិសោធននិវត្តន៍ និងពិការភាព និងសេវាកម្មអត្ថប្រយោជន៍ក្រោយចូលនិវត្តន៍ដែលមិនតម្រូវឱ្យបង់ប្រាក់ភ្លាមៗជូនអ្នកទទួលផល។ ការព្យួររយៈពេលពីរឆ្នាំនៃដែនកំណត់បំណុលរដ្ឋាភិបាលបានផុតកំណត់កាលពីថ្ងៃសៅរ៍ សប្តាហ៍មុន ដោយកំណត់ឡើងវិញនូវកម្រិតបំណុលបច្ចុប្បន្នប្រមាណ ២៨,៥ ទ្រីលានដុល្លារ។

ជាមួយគ្នានេះ ការិយាល័យថវិកាសភា(CBO) បានប៉ាន់ប្រមាណថាវិធានការណ៍វិសាមញ្ញនេះ អាចទាញត្រឡប់មកវិញនូកម្រិតប្រាក់កម្ចីដល់ទៅជាង៣៤០ប៊ីលានដុល្លារតាមការកំណត់ថ្មីនេះ។ CBO បានលើកឡើងថាបើរួមបញ្ចូលជាមួយសមតុល្យសាច់ប្រាក់បច្ចុប្បន្នរបស់រតនាគារ ប្រហែល ៤៥៩ ប៊ីលានដុល្លារ នឹងអនុញ្ញាតឱ្យរដ្ឋាភិបាលចៀសវាងការទូទាត់យឺតយ៉ាវនៅខែតុលា ឬ ខែវិច្ឆិកា។ លោកស្រី Yellen បានព្រមានសភានៅចុងខែកក្កដាថា កាលបរិច្ឆេទសំខាន់អាចជាថ្ងៃទី១ ខែតុលា នៅពេលដែលរដ្ឋាភិបាល ប្រឈមនឹងការបង់ប្រាក់ជាទឹកប្រាក់ចំនួន ១៥០ប៊ីលានដុល្លារនៅពេលដែលឆ្នាំសារពើពន្ធ ២០២២ ចាប់ផ្តើម។

ដោយឡែក រតនាគារ ត្រូវបានតម្រូវទៅតាមច្បាប់ដើម្បីធានាឲ្យមានមូលនិធិទាំងមូល នៅពេលដែលសភាអនុម័តលើដែនកំណត់កម្ចីថ្មី។ *ដោយ វត្ថា វង្សវឌ្ឍនៈ ប្រភព៖ គេហទំព័រសារព័ត៌មាន Rruters ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១*

## តិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៩ ខែសីហា ឆ្នាំ២០២១

- អត្រាអតិផរណាប្រចាំឆ្នាំរបស់ប្រទេសចិនបានធ្លាក់ចុះដោយមិននឹកស្មានដល់ក្នុងខែមិថុនាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មអាល្លឺម៉ង់បានកើនឡើងនៅខែឧសភាឆ្នាំ ២០២១

ថ្ងៃអង្គារ៍ ទី១០ ខែសីហា ឆ្នាំ២០២១

- ចំណូលពន្ធនៅអាហ្សង់ទីន បានកើនឡើង ក្នុងខែមិថុនា ឆ្នាំ ២០២១
- អត្រានីកម្មភាព ធ្វើនៅក្នុងប្រទេសទួរគីបានថយ នៅក្នុងខែឧសភាឆ្នាំ ២០២១

ថ្ងៃពុធ ទី១១ ខែសីហា ឆ្នាំ២០២១

- អត្រានីកម្មភាព នៅក្នុងប្រទេសកូរ៉េខាងត្បូងថយចុះ នៅក្នុងខែមិថុនាឆ្នាំ ២០២១
- កំណើនអត្រាអតិផរណាតម្លៃទំនិញប្រើប្រាស់របស់ប្រទេសអ៊ីតាលី នៅខែកក្កដាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី១២ ខែសីហា ឆ្នាំ២០២១

- ឱនភាពថវិកា សហរដ្ឋអាមេរិក នៅខែមិថុនាឆ្នាំ ២០២១
- ផលិតផលក្នុងស្រុកសរុបរបស់ចក្រភពអង់គ្លេសបានធ្លាក់ចុះ នៅត្រីមាសទី ១ ឆ្នាំ ២០២១

ថ្ងៃសុក្រ ទី១៣ ខែសីហា ឆ្នាំ២០២១

- កំណើនអត្រានីកម្មភាព នៅប្រទេសបារាំង នៅត្រីមាសទី ១ នៃឆ្នាំ ២០២១
- អត្រាអតិផរណាតម្លៃទំនិញប្រើប្រាស់របស់ប្រទេសបារាំង នឹងមានភាពធូរស្រាល នៅក្នុងខែកក្កដាឆ្នាំ ២០២១៕